# ពេលវេលាឈប់សំរាកពី - ការងារដើម្បីបោះឆ្នោត -

ការិយាល័យបោះឆ្នោតបើកពីម៉ោង 7:00 ព្រឹក ដល់ម៉ោង 8:00 ល្ងាច រៀងរាល់ថ្ងៃបោះឆ្នោត។ បើលោកអ្នកត្រូវបានកំណត់ពេលអោយធ្វើការនៅពេលនោះ ច្បាប់ California អនុញ្ញាតអោយលោកអ្នកយកពេលពីរម៉ោងសំរាកពីការងារដើម្បីបោះឆ្នោត ដោយមិនបានបាត់បង់ការបង់ប្រាក់ខែណាមួយឡើយ។

លោកអ្នកអាចចំណាយពេលច្រើនប៉ុណ្ណាក៏បានដែលលោកអ្នកត្រូវការដើម្បីបោះឆ្នោត ប៉ុន្តែមានតែពីរម៉ោងនៃពេលនោះតែប៉ុណ្ណោះដែលនឹងត្រូវបានបង់ថ្លៃអោយ។

ពេលវេលាឈប់សំរាកពីការងារសម្រាប់បោះឆ្នោត អាចបានតែពេលដើមដំបូង ឬចុងបញ្ចប់នៃវេនការងារធម្មតារបស់លោកអ្នកតែប៉ុណ្ណោះ លើកលែងតែលោកអ្នកធ្វើការរៀបចំណាមួយទៀតជាមួយនិយោជករបស់លោកអ្នក។

ប្រសិនបើលោកអ្នកគិតថា លោកអ្នកនឹងត្រូវការពេលវេលាឈប់សំរាកពីការងារដើម្បីបោះឆ្នោត លោកអ្នកត្រូវតែជំរាបនិយោជករបស់លោកអ្នក យ៉ាងហោចណាស់ពីរថ្ងៃធ្វើការមុនការបោះឆ្នោត។

---

ក្រមបោះឆ្នោត California មាត្រា 14000

Secretary of State Alex Padilla, 1500 11th Street, 5th Floor, Sacramento, CA 95814

**(800) 345-VOTE (8683)** **www.sos.ca.gov**